RHAC



គោលការណ៍ណែនាំការពិភាក្សាវីដេអូគំនូរជីវចលសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក

# ជនមានពិការភាព និង រឿងផ្លូវភេទ

amaze | Advocates for Youth — Rights. Respect. Responsibility. | UNESCO | UNFPA

# អំពីគោលការណ៍ណែនាំនេះ

គោលការណ៍ណែនាំការពិភាក្សានេះ គឺជាឯកសារណែនាំមួយក្នុងចំណោមគោលការណ៍ណែនាំការពិភាក្សាទាំង៦ផ្សេងទៀត ដែលត្រូវបានបង្កើតឡើងសម្រាប់អ្នកអប់រំទាំងអស់ក្នុងការប្រើប្រាស់ដើម្បីអប់រំដល់ក្មេងជំទង់និង
យុវវ័យទាំងអស់ឲ្យបានយល់ដឹងអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

គោលការណ៍ណែនាំការពិភាក្សានីមួយៗបានបញ្ចូល វីដេអូគំនូរជីវចលអប់រំ សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ ដែលប្រើប្រាស់ជាសម្ភារៈសិក្សា បន្ថែមលើផែនការមេរៀនដែលមានស្រាប់ ដើម្បីផ្តល់ពត៌មានទាក់ទងនឹងសុខភាពផ្លូវភេទ សុខភាពបន្តពូជ ទៅកាន់យុវវ័យ។ ការណែនាំអំពីវីដេអូពិភាក្សានីមួយៗ រួមបញ្ចូលមាន ការណែនាំពីប្រធានបទ ការចាក់បញ្ចាំងវីដេអូ សំណួរពិភាក្សា ការផ្តល់មតិត្រលប់ សកម្មភាព ឬល្បែងពង្រឹងស្មារតី សំណួរ-ចម្លើយ។

# ជនមានពិការភាព និង រឿងផ្លូវភេទ

## គោលបំណង

ដើម្បីឲ្យយុវជនយល់ដឹងអំពីជនមានពិការភាពក៏មានអារម្មណ៍ផ្លូវភេទ និងមនោសញ្ចេតនាដូចជនដទៃទៀតដែរ ពួកគេក៏ចង់ដឹង ចង់ឮ ពាក់ព័ន្ធនឹងទំនាក់ទំនងស្នេហា និងរាងកាយរបស់ពួកគេ ហើយពួកគេអាចយល់អំពី និន្នាការផ្លូវភេទ តាមរយៈវីដេអូគំនូរជីវចល ព្រមទាំងចូលរួមការពិភាក្សា និងការផ្ដល់ឱកាសក្នុងការបញ្ចេញមតិ។

## ដំហានស្នូល៖

ណែនាំប្រធានបទ (៥នាទី)

បង្ហាញវីដេអូគំនូរជីវចល (៤នាទី)

ការសម្របសម្រួលការពិភាក្សា និងសំនួរត្រិះរិះ (១៥នាទី




សកម្មភាពបន្ថែម ដូចជា សំណួរចម្លើយ ឬល្បែងពង្រឹងស្មារតី (១០នាទី)

បញ្ចប់សេចក្ដីដោយសង្ខេប ចំណុចសំខាន់ៗ (៥នាទី)

## ក្រុមគោលដៅ៖

ក្មេងជំទង់ និងយុវវ័យ ចាប់ពីអាយុ១០ឆ្នាំ ទៅ១៨ឆ្នាំ។

## រយៈពេល៖

៣០ - ៤០ នាទី

## សម្ភារៈបន្ថែម

- តំណភ្ជាប់វីដេអូ៖ https://youtu.be/UeT9M0N33-Q

**សម្រាប់សកម្មភាពផ្ទាល់ អ្នកនឹងត្រូវការសម្ភារៈដូចជា៖**

- កុំព្យូទ័រដែលមានវីដេអូស្រាប់ ឬមានអ៊ីនធឺណេត និងឧបករណ៍បំពងសំឡេង
- ម៉ាស៊ីនបញ្ចាំង LCD និងអេក្រង់ ឬតុសម្រាប់ដាក់កុំព្យូទ័ររបស់អ្នក។
- ក្រដាសស្ទីគ័រ ក្រដាសរឹង ឬក្ដាខៀន និងប៊ិចចម្រុះពណ៌សម្រាប់ការពិភាក្សា

# ជនមានពិការភាព និង រឿងផ្លូវភេទ

## សេចក្តីផ្តើម

មនុស្សគ្រប់រូបគឺសុទ្ធតែគិតរឿងផ្លូវភេទ នេះមិនពាក់ព័ន្ធនឹងសមត្ថភាពរបស់ពួកគេឡើយ។ ឥឡូវ តោះ! មើលវីដេអូដែលមានចំណងជើងថា«ជនមានពិការភាព និងរឿងផ្លូវភេទ» ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ ថាតើជនមានពិការភាព គិតអំពីរឿងផ្លូវភេទ មនោសញ្ចេតនាស្នេហា សេចក្តីត្រូវការ ចំណង់ ទំនាក់ទំនងស្នេហា ប្រកបដោយផាសុខភាពដូចអ្នកដទៃដោយរបៀបណា។

## សំណួរពិភាក្សា និងសំណួរត្រិះរិះ

បន្ទាប់ពីបញ្ចាំងវីដេអូ សូមដឹកនាំកិច្ចពិភាក្សាដោយប្រើសំណួរដូចខាងក្រោម។ បន្តកិច្ចពិភាក្សាទៅតាមពេលវេលាបានកំណត់ ហើយជ្រើសរើសសំណួរអាទិភាពដែលអ្នកចង់ពិភាក្សា។

១. តើអ្នកគិតយ៉ាងដូចម្តេចក្រោយពីការទស្សនាវីដេអូនេះ? តើអ្នកមានប្រតិកម្មយ៉ាងដូចម្តេចនៅពេលមើលវីដេអូនេះ?

២. តើជនមានពិការភាពជួបប្រទះនូវបញ្ហាអ្វីខ្លះ ទាក់ទងទៅនឹងរឿងមនោសញ្ចេតនាមើលចិត្តគ្នា ឬការណាត់ជួបជាមួយនរណាម្នាក់? ហើយតើពួកគេ ជម្នះឧបសគ្គទាំងនោះដោយរបៀបណា?

៣. ហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់មនុស្សគ្រប់រូប ក្នុងការរៀនអំពីការរួមភេទ និងសុខភាពផ្លូវភេទ បើទោះបីជាគាត់មានពិការភាពក៏ដោយ?

៤. តើអ្នកគួរធ្វើដូចម្តេច ប្រសិនបើមិត្តភ័ក្តិរបស់ពួកអ្នកដែលមានពិការភាព ត្រូវអ្នកដទៃវាយតម្លៃ ទាក់ទងនឹងសមត្ថភាពផ្លូវភេទ និងទំនាក់ទំនងស្នេហារបស់គេ?

៥. តើអ្វីជាគន្លឹះសំខាន់ៗដែលអ្នកបានរៀនពីវីដេអូ និងការពិភាក្សានេះ?

### ចំណាំ៖

សូមលើកទឹកចិត្តឱ្យមានការចូលរួមសកម្មពីអ្នកចូលរួមប៉ុន្តែវាក៏មិនជាបញ្ហាដែរប្រសិនបើអ្នកចូលរួមខ្លះមិនសូវមានទំនុកចិត្តក្នុងការនិយាយ - កុំបង្ខំពួកគេឱ្យឆ្លើយ ប្រសិនបើពួកគេមិនចង់។ អ្នកក៏អាចប្រើក្រដាសស្ទីកគ័រ ដើម្បីឲ្យអ្នកចូលរួមអាចសរសេរគំនិតរបស់ពួកគេដោយមិនបញ្ចេញឈ្មោះ។

### អ្វីដែលគួរធ្វើ!

- គោរពនូវការបញ្ចេញមតិយោបល់របស់អ្នកចូលរួមដ៏ទៃទៀត
- ស្តាប់ដោយយកចិត្តទុកដាក់
- ប្រើពាក្យពេជន៍ដែលមិនបង្ករអោយមានការរើសអើងភេទ និង យេនឌ័រ
- ផ្តល់ឱកាសឲ្យគ្រប់គ្នាបានឆ្លើយសំនួរ ឬចែករំលែកនូវការយល់ឃើញរបស់ពួកគេ
- រំលឹកអ្នកចូលរួមទាំងអស់ឱ្យគោរពគ្នាទៅវិញទៅមក និងស្តាប់ដោយយកចិត្តទុកដាក់

### កំណត់ចំណាំពិសេសសម្រាប់មិត្តអប់រំមិត្ត៖

- ត្រូវប្រុងប្រយ័ត្នចំពោះការប្រើពាក្យពេជន៍ទាក់ទងនឹងជនមានពិការភាព។ អ្នកអាចប្រើពាក្យ 'ជនមានពិការភាព' ឬ 'សមត្ថភាពខុសគ្នា' ជាជាងប្រើពាក្យ 'ជនពិការ' ។ ទោះជាយ៉ាងណានេះក្តី វាជាការចាំបាច់ក្នុងការ ក្នុងការសួរទៅកាន់អ្នកចូលរួមពីភាសារដែលពួកគេចង់ប្រើ។
- ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះតម្រូវការចាំបាច់របស់អ្នកចូលរួម។អ្នកចូលរួមខ្លះអាចត្រូវការការរៀបចំអោយមានភាពងាយស្រួលជូនពួកគេ ដើម្បីឲ្យពួកគេចូលរួមក្នុងការពិភាក្សា ឬសកម្មភាពផ្សេងៗបាន។ តួយ៉ាង អ្នកអាចសម្រួលទីធ្លាកន្លែងអង្គុយដល់ អ្នកចូលរួមដែលមានពិការភាព ដើម្បីឲ្យគាត់អាចធ្វើការចល័ត ឬធ្វើចលនាបាន។





## សកម្មភាពបន្ថែម៖

សកម្មភាពនេះអាចជួយអោយអ្នកចូលរួមអាចផ្ដោតទៅលើមេរៀនកាន់តែងាយស្រួល និងចងចាំបានល្អបន្ទាប់ពីមើលវីដេអូរួច។ មធ្យោបាយអន្តរកម្មរហ័សសម្រាប់អ្នកចូល។ សូមពន្យល់អ្នកចូលរួមថា អ្នកនឹងអានប្រយោគមួយចំនួនដែលបង្ហាញពីការលើកឡើង កាពិត ឬជំនឿមិនត្រឹមត្រូវប៉ុណ្ណោះ។
អ្នកចូលរួមអាចលើកដៃឡើង ប្រសិនបើពួកគេគិតថា ប្រយោគនេះជាការពិត ឬដាក់ដៃចុះបាន ប្រសិនបើពួកគេគិតថាវាមិនពិត គ្រាន់តែជាជំនឿមិនត្រឹមត្រូវប៉ុណ្ណោះ។

https://bit.ly/kahoot_disabilityandsexuality
ការពិត ឬជំនឿមិនត្រឹមត្រូវ៖

១. ជនមានពិការភាពមានចំណង់ផ្លូវភេទ ហើយវាជារឿងធម្មតា។ (ពិត)
២. ជនមានពិការភាពមិនមានការណាត់ជួបជាមួយមនុស្សដែលគេពេញចិត្តទេ។ (មិនពិត)
៣. ជនមានពិការភាពអាចមាននិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រផ្សេងៗពីគ្នា។ (ពិត)
៤. ជនមានពិការភាពអាចប្រឈមនឹងបញ្ហា ដែលមនុស្សទូទៅប្រហែលជាអាចជួបប្រទះដែរ ដូចជា ការហួងហែងហួសហេតុពីឪពុកម្ដាយជាដើម។ (ពិត)
៥. យុវជនគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានសុខភាពផ្លូវភេទ និងការទទួលបានសេវា សុខភាពផ្លូវភេទ ដោយមិនគិតពីពិការភាព ។ (ពិត)





## សង្ខេបគន្លឹះសំខាន់ៗ

បញ្ចប់វគ្គដោយបញ្ជាក់ពីចំណុចសំខាន់ៗដូចខាងក្រោម៖

ជនមានពិការភាពក៏មានអារម្មណ៍ផ្លូវភេទ មនោសញ្ចេតនាស្នេហា និងទំនោរផ្លូវភេទ ដូចអ្នកដទៃទៀតដែរ។ពួកគេមានតម្រូវការ និងចំណង់ផ្លូវភេទដូចគ្នាទៅនឹងមនុស្សផ្សេងទៀត ហើយពួកគេអាចមានទំនោរផ្លូវភេទខុសៗគ្នា (អ្នកស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ភេទផ្ទុយគ្នាស្រឡាញ់មិនរើសភេទជាដើម)។នៅក្នុងទំនាក់ទំនងស្នេហាអ្នកមានពិការភាពក៏ចង់បានការគោរពការយល់ព្រមការប្រាស្រ័យទាក់ទងគ្នា និងភាពរីករាយដូចគ្នានឹងមនុស្សទូទៅដែរ ហេតុនេះហើយមនុស្សគ្រប់រូប មិនថាជាជនពិការ ឬមិនពិការនោះទេ ចាំបាច់ត្រូវយល់ដឹងអំពីការបង្ហាញអារម្មណ៍មនោសញ្ចេតនាស្នេហាទៅកាន់ដៃគូទើបទំនាក់ទំនងស្នេហាប្រកបដោយសេចក្តីរីករាយព្រមទាំងសុខភាពផ្លូវភេទនិងរៀនទទួលយកនូវការបដិសេធ។ទោះជាយ៉ាងនេះក្តីជនមានពិការភាពភាគច្រើនអាចប្រឈមនឹងបញ្ហាមួយចំនួនដូចជា ការការពារហួសហេតុពីសំណាក់ឪពុកម្តាយ ឬ មិត្តភក្តិដែលយល់ច្រឡំអំពីពិការភាពរបស់ពួកគេ ដោយមានផលលំបាកក្នុងការបង្ហាញអារម្មណ៍ចេញមកក្រៅ និងការព្រមព្រៀងដោយពាក្យសំដីជាដើម។ លើសពីនេះទៀត យុវជនដែលមានពិការភាពផ្នែកបញ្ញា នៅក្នុងបរិបទជាច្រើនពួកគេមិនអាចផ្តល់ការយល់ព្រមតាមផ្លូវច្បាប់ចំពោះការរួមភេទបានទេ ហើយពួកគេអាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទដោយបុគ្គលណាម្នាក់ (រួមទាំងមិត្តភក្តិ) ដែលសម្លឹងឃើញផលប្រយោជន៍ពីពិការភាពរបស់ពួកគេ។ ប្រសិនបើអ្នកជាយុវជនដែលមានពិការភាពការអប់រំរឿងផ្លូវភេទអាចជួយផ្តល់ព័ត៌មានអំពីរបៀបនៅក្នុងការប្រាស្រ័យទាក់ទងទៅកាន់ដៃគូ ទំនាក់ទំនងស្នេហាប្រកបដោយផាសុខភាព និងអ្វីផ្សេងជាច្រើនទៀត។ ការប្រឹក្សាជាមួយឪពុកម្តាយ អាណាព្យាបាល អ្នកផ្តល់សេវាថែទាំសុខភាព ឬមនុស្សពេញវ័យដែលអាចទុកចិត្តផ្សេងទៀតអំពីវិធីទទួលបានការអប់រំផ្លូវភេទដែលអ្នកត្រូវការ។

សូមជួយផ្សព្វផ្សាយចំណេះដឹងនេះទៅកាន់យុវជនដទៃទៀតដើម្បីឱ្យមនុស្សកាន់តែច្រើនស្វែងយល់អំពី រឿងផ្លូវភេទគឺជារឿងដែលមនុស្សគ្រប់រូបសុទ្ធគិត និងនិយាយអំពីវា ។




**Co-created by
Maryada Neupane,
Naura Haryanto,
and Vouchleang Chhun.**